**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល
លេខ...១៤០...ស.ខ.ល

# សេចក្តីជូនដំណឹង
# របស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩
# ស្តីពី
# យន្តការស្នើសុំចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដោយស្ម័គ្រចិត្ត
# សម្រាប់ជនបរទេសនៅប្រទេសកម្ពុជា

ដើម្បីឱ្យកិច្ចដំណើរការរៀបចំចាក់វ៉ាក់សាំងជូនជនបរទេសដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសកម្ពុជា ប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងទាន់ពេលវេលា គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានរៀបចំយន្តការក្នុងការស្នើសុំចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្តជូនដល់ជនបរទេសដែលកំពុងរស់នៅ ឬកំពុងបម្រើការងារនៅក្នុងប្រទេសកម្ពុជា ដែលមិនស្ថិតនៅក្រោមឆ័ត្រអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការទូតការគី ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ស្ថានទូតនៅកម្ពុជា ឬអង្គការស្របច្បាប់ក្នុងស្រុក (ដែលមានការសម្របសម្រួលដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) មានដូចខាងក្រោម៖

ក. **ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** ទទួលខុសត្រូវរៀបចំបញ្ជីឈ្មោះជនបរទេស ដែលកាន់ទិដ្ឋាការធម្មតា ប្រភេទ(E) ហើយដែលមានប័ណ្ណការងារ (work permits) ចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមមាន៖ វិនិយោគិន ធុរជន ពលករជំនាញ សិល្បករ គ្រូពេទ្យ គ្រូបង្រៀន កីឡាករ ទីប្រឹក្សានានា អ្នកជំនាញការបរទេស ។ល។

- ឯកសារតម្រូវ សម្រាប់ស្នើសុំចាក់វ៉ាក់សាំង៖
  - ១. លិខិតឆ្លងដែនមានសុពលភាព
  - ២. ទិដ្ឋាការដែលមានសុពលភាព
  - ៣. ប័ណ្ណការងារ (work permits) ដែលចេញដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជនបរទេសក្នុងប្រភេទ(ក) ដែលបានស្នើសុំចាក់វ៉ាក់សាំង នឹងទទួលបានការជូនព័ត៌មានចាក់វ៉ាក់សាំងជាមុន ដែលការចាក់អាច ស្របពេលជាមួយនឹងមន្ត្រី-បុគ្គលិក និងកម្មករ នៅតាមក្រសួង ស្ថាប័ន រោងចក្រ ក្រុមហ៊ុន ឬទីកន្លែងសមស្របតាមកម្មវិធីចាក់វ៉ាក់សាំង របស់ក្រសួងសុខាភិបាល។

**ខ. អាជ្ញាធរមូលដ្ឋាន** រាជធានី ខេត្ត ក្រុងទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាអ្នកទទួលខុសត្រូវរៀបចំបញ្ជីឈ្មោះជនបរទេសផ្សេងទៀត ដែលមិនស្ថិតក្នុង **ប្រភេទ** (ក) រួមមាន៖ ពលរដ្ឋខ្មែរដែលកាន់លិខិតឆ្លងដែនបរទេស (មានទិដ្ឋាការពិសេសប្រភេទ K) ជនបរទេសដែលបានរៀបការជាមួយពលរដ្ឋខ្មែរ ជនបរទេសចូលនិវត្តន៍ ជនបរទេសស្នាក់នៅស្របច្បាប់ រយៈពេលវែង ។ល។

- ឯកសារតម្រូវសម្រាប់ចុះឈ្មោះចាក់វ៉ាក់សាំង៖
    ១. លិខិតឆ្លងដែនមានសុពលភាព
    ២. ទិដ្ឋាការដែលមានសុពលភាព ។

ជនបរទេសក្នុងប្រភេទ(ខ) នឹងទទួលការចាក់វ៉ាក់សាំង ស្របពេលជាមួយនឹងពលរដ្ឋខ្មែរ នៅតាមទីកន្លែងសមស្រប តាមកម្មវិធីចាក់វ៉ាក់សាំងរបស់ក្រសួងសុខាភិបាល។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជា**

**ប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩**

**ម៉ម ប៊ុនហេង**

*(Unofficial Translation from the Khmer Version)*

**ANNOUNCEMENT**
**of the Inter-Ministerial Committee to Fight Covid-19**
**on**
**Request Mechanism of Voluntary COVID-19 Vaccination**
**for Foreigners in Cambodia**

---------------

In order to ensure effective and orderly vaccination process for foreigners who are residing and working in Cambodia and who are not under the umbrella of the United Nations (UN), International Organizations (IOs), Bilateral Organization, International Financing Institutions, Embassy in Cambodia or recognized legally local organizations (they are under the coordination and facilitation by the Ministry of Foreign Affairs and International Cooperation), the request mechanism of voluntary COVID-19 vaccination is instructed by the Inter-Ministerial Committee to Fight Covid-19 as follows:

**A. The Ministry of Labour and Vocational Training** (MLVT) is responsible for preparing the registration list of foreigners holding Ordinary Visa (Visa E) and Work Permits issued by the MLVT, including investors, businesspersons, skilled workers, artists, medical practitioners, teachers, sport practitioners, advisors, experts, etc.

The required documents for the vaccination registration are (1) valid passport, (2) valid Visa and (3) valid Work Permits issued by the MLVT.
The foreigners in category (A) who have been registered for vaccination will receive a notification for vaccination that may receive vaccination at the same time with Cambodian officials and workers at ministries, institutions, factories, companies, or appropriate locations, in compliance with the vaccination programme of the Ministry of Health.

**B. The local authorities** at the level of capital, provinces and cities in the Kingdom of Cambodia, are responsible for the registration of other foreigners who are not listed in the category (A): Khmer citizens holding foreign passports with Visa (K), foreigners married to Khmer citizens, foreign retirees, foreigners with legal long-term residence etc.

The required documents for the vaccination registration are (1) valid passport and (2) valid Visa.
The foreigners in category (B) who have been registered for vaccination will receive a vaccination at the same time with Khmer citizens at appropriate locations, in compliance with the vaccination programme of the Ministry of Health.

Phnom Penh, 08 April 2021